**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តសៀមរាប**

ថ្ងៃសុក្រ ៩កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ខេត្តសៀមរាប ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន

រដ្ឋបាលខេត្តសៀមរាប មានកិត្តិយស សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៤ តំណាងអាជ្ញាធររដ្ឋបាលខេត្តសៀមរាប បានជួបពិភាក្សាការងារជាមួយបងប្អូនអ្នកប្រកបរបរដឹកជញ្ជូនភ្ញៀវទេសចរប្រមាណជិត១០០នាក់ ។ នៅក្នុងជំនួបនេះ រដ្ឋបាលខេត្តបានទទួលយកសំណូមពររបស់បងប្អូនជុំវិញការកំណត់ថ្លៃសេវាប្រើប្រាស់ផ្លូវ និងចំណតយានយន្តនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ ដែលរហូតមកដល់ពេលនេះ រដ្ឋបាលខេត្ត បានបញ្ជូនសំណើទាំងនោះជូនដល់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងពិចារណាពីទិដ្ឋភាពបច្ចេកទេស និង ទិដ្ឋភាពច្បាប់ ក្នុងការរកដំណោះស្រាយជូនបងប្អូន។ រដ្ឋបាលខេត្តនឹងជម្រាបជូនព័ត៌មានបន្ថែមទៀតអំពីលទ្ធផលនៃការពិភាក្សា និងការសម្រេចចិត្តនានា ក្នុងក្របខ័ណ្ឌនៃការដោះស្រាយសំណូមពររបស់បងប្អូននាពេលបន្ទាប់។

រដ្ឋបាលខេត្ត ក៏នៅតែបន្តស្វាគមន៍ចំពោះកិច្ចសន្ទនា ក្នុងបំណងដោះស្រាយការលំបាករបស់បងប្អូន ដែលជាកាយវិការឆ្លុះបញ្ចាំងអំពីរបៀបធ្វើការប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងសេចក្តីថ្លៃថ្នូរ ដើម្បីបង្កើតបរិយាកាសល្អប្រសើរ  មិនធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ដំណើរការផ្តល់សេវាកម្មលើវិស័យទេសចរណ៍ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការទាក់ទាញភ្ញៀវទេសចរមកទស្សនាកម្សាន្តនៅតំបន់អង្គរ និងតំបន់នានាក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែច្រើនឡើង ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ដោយផ្តោតជាអាទិភាពលើវិស័យទេសចរណ៍ ជាប៉ូលសេដ្ឋកិច្ចមួយដ៏សំខាន់របស់ប្រទេសយើង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

**រដ្ឋបាលខេត្តសៀមរាប**

សាលាខេត្តសៀមរាប ផ្លូវលេខ C.400 ភូមិឆ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប Siem Reap Provincial Hall, Street C.400, Thlok Angdoung Village, Sangkat Slakram, Siem Reap Municipality, Siem Reap Province, Email: srphall@siemreap.gov.kh,Tel: (855) 63 212 999